**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៥០១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

## ការកាត់ដីទំហំ ១៣,៩២ ហិកតា នៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ២៦គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ



www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៤៧០ អបខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ១៣,៩២ ហិកតា ចេញពីដីតម្រូវព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មដីទំហំ ១៣,៤០ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ០,៥២ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិពង្រ ឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២៦គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅភូមិពង្រ ឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ.៥៧១.អនក្រ.បក ចុះថ្ងៃទី.០៤...ខែ.វិច្ឆិកា.ឆ្នាំ២០១៣ ស្តីពីការកាត់ឆ្វៀលដីសរុបទំហំ ១៣,៩២ហិកតា ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២៦គ្រួសារ លើផ្ទៃដីទំហំ ១៣,៤០ហិកតា ដែលបានកាន់កាប់ ប្រើប្រាស់ និងជាំជុះជាក់ស្តែង និងដីទំហំ ០,៥២ហិកតា ក្បោនុកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភូមិពាម ឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ



**តារាងចំណុចនិយាមការ**

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 446819 | 1241800 | 48 | 447007 | 1242023 |
| 2 | 446826 | 1241833 | 49 | 447006 | 1242009 |
| 3 | 446836 | 1241848 | 50 | 447004 | 1241971 |
| 4 | 446840 | 1241891 | 51 | 446987 | 1241973 |
| 5 | 446840 | 1241897 | 52 | 446980 | 1241960 |
| 6 | 446845 | 1241941 | 53 | 447014 | 1241955 |
| 7 | 446841 | 1241942 | 54 | 447015 | 1241973 |
| 8 | 446836 | 1241963 | 55 | 447029 | 1241969 |
| 9 | 446836 | 1241984 | 56 | 447033 | 1241970 |
| 10 | 446827 | 1241991 | 57 | 447035 | 1241973 |
| 11 | 446830 | 1242003 | 58 | 447050 | 1241972 |
| 12 | 446846 | 1241993 | 59 | 447060 | 1241967 |
| 13 | 446848 | 1241999 | 60 | 447057 | 1241944 |
| 14 | 446851 | 1242014 | 61 | 447078 | 1241938 |
| 15 | 446864 | 1242014 | 62 | 447071 | 1241881 |
| 16 | 446865 | 1242045 | 63 | 447172 | 1241842 |
| 17 | 446874 | 1242080 | 64 | 447195 | 1241817 |
| 18 | 446877 | 1242095 | 65 | 447212 | 1241820 |
| 19 | 446882 | 1242097 | 66 | 447289 | 1241802 |
| 20 | 446886 | 1242096 | 67 | 447325 | 1241783 |
| 21 | 446891 | 1242104 | 68 | 447347 | 1241748 |
| 22 | 446868 | 1242106 | 69 | 447342 | 1241740 |
| 23 | 446885 | 1242118 | 70 | 447337 | 1241746 |
| 24 | 446866 | 1242116 | 71 | 447307 | 1241747 |
| 25 | 446867 | 1242133 | 72 | 447302 | 1241728 |
| 26 | 446868 | 1242145 | 73 | 447255 | 1241745 |
| 27 | 446867 | 1242153 | 74 | 447233 | 1241719 |
| 28 | 446868 | 1242167 | 75 | 447224 | 1241710 |
| 29 | 446919 | 1242159 | 76 | 447219 | 1241697 |
| 30 | 446931 | 1242145 | 77 | 447209 | 1241700 |
| 31 | 446951 | 1242141 | 78 | 447189 | 1241677 |
| 32 | 446984 | 1242133 | 79 | 447177 | 1241618 |
| 33 | 447009 | 1242135 | 80 | 447164 | 1241604 |
| 34 | 447068 | 1242132 | 81 | 447149 | 1241553 |
| 35 | 447065 | 1242111 | 82 | 447097 | 1241569 |
| 36 | 447039 | 1242112 | 83 | 447101 | 1241585 |
| 37 | 447038 | 1242102 | 84 | 447084 | 1241592 |
| 38 | 446983 | 1242109 | 85 | 447070 | 1241604 |
| 39 | 447002 | 1242093 | 86 | 447061 | 1241593 |
| 40 | 446991 | 1242098 | 87 | 447018 | 1241615 |
| 41 | 446982 | 1242096 | 88 | 446971 | 1241614 |
| 42 | 446999 | 1242085 | 89 | 446939 | 1241621 |
| 43 | 447004 | 1242078 | 90 | 446943 | 1241698 |
| 44 | 446999 | 1242066 | 91 | 446933 | 1241739 |
| 45 | 447022 | 1242045 | 92 | 446928 | 1241757 |
| 46 | 447017 | 1242034 | 93 | 446921 | 1241769 |
| 47 | 447009 | 1242032 | 94 | 446813 | 1241770 |

**សញ្ញាសំគាល់**

- ភូមិ
- សាលាឃុំ
- សាលាស្រុក
- ស្ទឹង/អូរមានទឹកជាប្រចាំ
- ស្ទឹង/អូរមានទឹកនៅរដូវវស្សា
- ប្រឡាយ
- ផ្លូវចាក់កៅស៊ូ
- ផ្លូវគ្រួសក្រហម ឬ ក្រាលថ្ម
- ផ្លូវរទេះ ឬ ផ្លូវដើរ

មាត្រដ្ឋាន 1:3,500

200 100 0 Meters

Coordinate System : UTM , Zone : 48N
Horizontal Datum : WGS_84 , Grid : 100m

